# សេចក្តីប្រកាសព័ត៌មាន

# ប្រទេសកម្ពុជា ស៊ុយអែត និងយូនីសេហ្វ រួមគ្នាការពារការអប់រំសម្រាប់កុមារ ដែលសាលារៀនខ្លួនត្រូវបានប្រើប្រាស់ជាមជ្ឈមណ្ឌលចត្តាឡីស័ក

**រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១៖** ក្រសួងអប់រំ យុវជន និងកីឡា និងយូនីសេហ្វកំពុងរិះរកវិធីឆ្លើយតបបន្ទាន់ចំពោះតម្រូវការសិក្សារបស់សិស្សានុសិស្សដែលពុំអាចទៅរៀនបាន ដោយសារសាលារបស់ពួកគេកំពុងត្រូវបានប្រើប្រាស់ជាមជ្ឈមណ្ឌលចត្តាឡីស័កជំងឺកូវីដ១៩។ ទោះជាបវេសនកាលឆ្នាំសិក្សាថ្មី ត្រូវបានចាប់ផ្តើមកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ក៏ដោយ មានសាលាបឋមសិក្សាចំនួន១៣ អនុវិទ្យាល័យចំនួន១៨ និងវិទ្យាល័យចំនួន១៩ ដែលមានទីតាំងនៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ ពុំអាចបើកដំណើរការព្រមគ្នាជាមួយនឹងសាលារៀនដទៃទៀតឡើយព្រោះសាលារៀនទាំងនោះកំពុងត្រូវបានប្រើប្រាស់ជាមជ្ឈមណ្ឌលចត្តាឡីស័ក សម្រាប់ពលករចំណាកស្រុកកម្ពុជា ដែលបានវិលត្រឡប់ពីប្រទេសថៃ។ សកម្មភាពនេះគឺជាកិច្ចខិតខំប្រឹងប្រែងបន្តរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា″ យើងស្វាគមន៍ចំពោះការគាំទ្របន្ថែមពីយូនីសេហ្វ និងប្រទេសស៊ុយអែត សម្រាប់សាលារៀន និងសិស្សានុសិស្សដែលរងផលប៉ះពាល់ក្នុងខេត្តនានានៅជាប់ព្រំដែន។ ទោះបីជាយើងកំពុងជួបប្រទះការលំបាកពីការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ១៩ក៏ដោយ ក៏យើងត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីឱ្យសិស្សអាចនៅតែបន្តការសិក្សាបាន និងធានាថាពួកគេមានសុវត្ថិភាពពីជំងឺនេះ។ ដូច្នេះហើយបានជាការផ្តល់សៀវភៅសិក្សានៅពេលនេះដល់សិស្សដែលរងផលប៉ះពាល់ គឺជាអន្តរាគមន៍ចំពោះមុខដ៏មានសារៈសំខាន់ ដើម្បីជួយឱ្យពួកគេនៅតែបន្តការសិក្សាបាន។″

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការវាយតម្លៃរហ័សមួយលើតម្រូវការរបស់សិស្សានុសិស្សដែលរងផលប៉ះពាល់ ហើយបានរកឃើញថា ការខ្វះសៀវភៅសិក្សាគឺជាបញ្ហាប្រឈមធំជាងគេបំផុតមួយ ដែលសិស្សានុសិស្សកំពុងជួបប្រទះ ជាពិសេសសិស្សដែលត្រូវរៀនពីចម្ងាយនៅតាមផ្ទះ ឬដែលត្រូវទៅរៀននៅសាលាមួយទៀត នៅក្បែរសាលារៀនខ្លួន ។ ដើម្បីឆ្លើយតបចំពោះតម្រូវការនេះ យូនីសេហ្វ ដោយមានការគាំទ្រថវិកាពីប្រទេសស៊ុយអែត បានទិញសៀវភៅសិក្សាមុខវិជ្ជាគោលសម្រាប់ចែកជូនសិស្សនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យចំនួន៥០ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ ជាសរុប សៀវភៅសិក្សាចំនួន ៣៥.០៥៥ ក្បាល ត្រូវបានចែកជូនទៅ

ដល់សាលារៀននៅតំបន់ភាគឦសាន ដែលបានជួយដល់សិស្សប្រមាណ ៣២.៤៨៦នាក់ ឱ្យអាចបន្តការសិក្សារបស់ពួកគេបាន។

ឯកឧត្តម **ប៊ីយ៉ន ហ៊ែហ្គម៉ាយ** ឯកអគ្គរាជទូតប្រទេសស៊ុយអែតប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "ការអប់រំគឺជាសិទ្ធិមនុស្សមូលដ្ឋានដ៏សំខាន់ ប៉ុន្តែការរាតត្បាតនៃជំងឺកូវីដ១៩ បានបន្តបង្អាក់ដល់ការសិក្សារបស់កុមារកម្ពុជារាប់ពាន់នាក់។ ប្រទេសស៊ុយអែតមានសេចក្តីសោមនស្សរីករាយ ដែលអាចចូលរួមជួយដល់ការឆ្លើយតបជាបន្ទាន់ដ៏មានសារៈសំខាន់នេះ ដើម្បីធានាថាកុមារី និងកុមារដែលរស់នៅក្នុងខេត្តរងផលប៉ះពាល់ផ្ទាល់ពីជំងឺកូវីដ១៩ អាចទទួលបានធនធនសិក្សាគ្រប់គ្រាន់ ដើម្បីបន្តការសិក្សារបស់ពួកគេ។"

នៅក្នុងឆ្នាំ២០២១ ដែលជាឆ្នាំទី២នៃការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ១៩ ថ្នាំបង្ការបាននាំមកនូវក្តីសង្ឃឹមថ្មីដល់យើង។ ប៉ុន្តែអត្រានៃការឆ្លងនៅតែមានកម្រិតខ្ពស់នៅឡើយ។ នៅក្នុងឆ្នាំ២០២០ ការអប់រំរបស់កុមារត្រូវបានរងប៉ះពាល់យ៉ាងខ្លាំងពីមេរោគរាតត្បាតនេះ ហើយជាលទ្ធផលមានសាលារៀនជាច្រើនត្រូវបានបិទទ្វារ។ យូនីសេហ្វ កំពុងធ្វើការតស៊ូមតិឱ្យបន្តការអប់រំនៅជុំវិញពិភពលោក និងកសាងឡើងវិញ និងគិតគូរសារជាថ្មីនូវប្រព័ន្ធអប់រំមួយដែលផ្តល់អត្ថប្រយោជន៍ដល់កុមារទាំងអស់ និងមានភាពធន់ទៅនឹងវិបត្តិនានានៅថ្ងៃអនាគត។

លោកស្រី **ហ្វ៊ូហ្គ ហ្វយូហ្សិច** នាយិកាយូនីសេហ្វប្រចាំកម្ពុជាបានមានប្រសាសន៍ថា "យូនីសេហ្វសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលស៊ុយអែត សម្រាប់កិច្ចសហការគាំទ្រដល់កុមារ នៅក្នុងស្ថានភាពដ៏បាកនេះ។ តម្រូវការចាំបាច់ដើម្បីឆ្លើយតបនឹងជំងឺកូវីដ១៩ បានធ្វើឱ្យមានការអាក់ខានដល់ការរៀនសូត្រ ប៉ុន្តែវាមានសារៈសំខាន់ណាស់ដែលយើងត្រូវគិតគូរសារជាថ្មីនូវការអប់រំ ដែលសមស្របទៅនឹងស្ថានភាពផ្លាស់ប្តូរទាំងនេះ។ កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ ហើយយើងត្រូវរួមគ្នាបំពេញនូវសិទ្ធិនោះឱ្យពួកគេ។" លោកស្រីក៏បានបន្ថែមទៀតថា "ខ្ញុំសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យពិនិត្យនូវជម្រើសដទៃទៀតក្នុងការគាំទ្រដល់ការវិលត្រលប់ប្រកបដោយសុវត្ថិភាពរបស់កម្មករចំណាកស្រុក ដោយចាត់ទុកការប្រើប្រាស់សាលារៀនជាមជ្ឈមណ្ឌលចត្តាឡីស័ក គួរតែជាជម្រើសចុងក្រោយ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ចេញពីការបិទសាលារៀនទាំងនោះ។"

<u>កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ</u>

**អំពីយូនីសេហ្វ**

យូនីសេហ្វកម្ពុជាធ្វើការងារ ដើម្បីលើកកម្ពស់ការអភិវឌ្ឍល្អប្រសើររបស់កុមារ ការពារសិទ្ធិរបស់ពួកគេ និងជួយឱ្យពួកគេសម្រេចសក្តានុពលចាប់ពីវ័យកុមារតូច រហូតដល់វ័យក្មេងជំទង់។

សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វ និងការងារដែលយូនីសេហ្វធ្វើដើម្បីកុមារ សូមចូលមើលគេហទំព័រ www.unicef.org។ សូមតាមព័ត៌មានអំពីយូនីសេហ្វ Twitter និង Facebook

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


- ឯកឧត្តមបណ្ឌិត រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា
  ទូរសព្ទ៖ +៨៥៥ ៧៨ ៧៥៥ ៥៥៦ ឬសារអេឡិកត្រូនិក៖ soveacha2002@yahoo.com
- អ្នកស្រី រ្វឌីណា វ៉ូវ៉ូដា ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរសព្ទ៖ (+៨៥៥) ៩២ ៥៥៥ ២៩៤ ឬ សារអេឡិកត្រូនិក៖ rvojvoda@unicef.org
- លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរសព្ទ៖ +៨៥៥ ១២ ៧៣៣ ៩០៩  ឬសារអេឡិកត្រូនិក៖ bmeas@unicef.org